អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D347/2/1/4

ក្នុងនាមប្រជារាស្ត្រខ្មែរ និងក្នុងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៧)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ណី ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 10 / 2017
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ (កោសលុប)

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់សម្ភារៈនៅក្នុងសំណុំរឿង ០០៤**

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍៖**

សូ មូស្សេនី
Susana TOMANOVIĆ
Neville SORAB

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

01539806



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤" ដែលមេធាវីការពារក្តី [redacted] ("សហមេធាវី" និង "ម្ចាស់បណ្តឹងឧទ្ធរណ៍") បានដាក់នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលណែនាំឱ្យដាក់សម្ភារៈ រួមមានវីដេអូ និងប្រតិចារឹកសវនាការពីសំណុំរឿង ០០២/០២ ព្រមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងផែនទី ពីសំណុំរឿង ០០៣ ទៅក្នុងសំណុំរឿង ០០៤ ("ដីកាសម្រេចដែលរងការជំទាស់")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្នុងអំពើព្រហ្មទណ្ឌ និងស្នើសុំឱ្យចោទប្រកាន់មកលើរូបគាត់[3]។

---

[1] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D347/2/1/2 ("បណ្តឹងឧទ្ធរណ៍") បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៧។ *សូមមើលផងដែរ* សំណើសុំការអនុញ្ញាតដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤ តែមួយភាសា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D347/2/1/1។

[2] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឯកសារក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D347/2 ("ដីកាសម្រេចដែលរងការជំទាស់")។

[3] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE

3. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយស្នើសុំដាក់សម្ភារៈនានាទៅក្នុងសំណុំរឿង ០០៤[4]។

4. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដែលរងការជំទាស់[5]។

5. នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៧ សហមេធាវីបានដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍[6] ហើយនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ ពួកគេបានដាក់សារណាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន[7]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧[8]។ ពុំមានសារណាតបត្រូវបានដាក់ក្នុងពេលវេលាកំណត់ទេ។

## III. ភាពឧទ្ទលយកបាន

### ក. សារណា

6. សហមេធាវីលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[9] ដោយសារស្ថានភាពដែលបានលើកឡើងក្នុងដីកាសម្រេចដែលរងការជំទាស់ មិនស្ថិតនៅក្នុងវិធានជាធរមាន[10] ហើយវារំលោភសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការចូលរួមទៅក្នុងកិច្ច

[4] សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់ផែនទី និងសម្ភារៈពីសំណុំរឿង ០០២ និង ០០៣ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D347។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ចម្លើយតបរបស់ [redacted] ទៅនឹង សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់ផែនទី និងសម្ភារៈពីសំណុំរឿង ០០២ និង ០០៣ ទៅក្នុងសំណុំរឿង ០០៤ (D347) ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៧។

[5] *សូមមើល ខាងលើ* ជើងទំព័រ ២។

[6] សំណុំរឿង ០០៤ ការជូនដំណឹងរបស់ [redacted] អំពីបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D347/2/1។

[7] *សូមមើល ខាងលើ* ជើងទំព័រ ១។

[8] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D347/2/1/3 ("ចម្លើយតប")។

[9] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០។

[10] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។



PRE-TRIAL CHAMBER CHAMBRE · E.C.C.C · C.E.T.C

ដំណើរការនីតិវិធីប្រឆាំងនឹងគាត់ និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្នុងរឿងក្ដី[11]។ ពួកគេអះអាងថា ការរំលោភសិទ្ធិនេះមានផលប៉ះពាល់ជាព្យសនកម្មភ្លាមៗ និងមិនអាចជួសជុលបាន ដោយសារការសន្និដ្ឋានអវិជ្ជមានអាចត្រូវធ្វើឡើងប្រឆាំងនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍ នៅក្នុងដីកាដំណោះស្រាយ ដោយផ្អែកលើប្រតិចារឹកក្នុងសំណុំរឿង ០០២ ដែលបានបញ្ចូលទៅក្នុងសំណុំរឿង ០០៤[12]។ ពួកគេសង្កត់ធ្ងន់បន្ថែមថា ប្រតិចារឹកក្នុងសំណុំរឿង ០០២ ត្រូវបានបញ្ចូលក្នុងសំណុំរឿង ០០៤ រួចហើយ ហើយថា ហេតុនេះ បញ្ហានេះមិនមែនជាសម្មតិកម្មទេ[13]។

7. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ[14] ដោយសារ ព្យសនកម្មដែលបានចោទប្រកាន់គឺជាសម្មតិកម្ម ហើយសូម្បីតែប្រសិនបើគាត់បានបង្ហាញពីការបំពាននេះក៏ដោយ ក៏វានឹងមិនបំពេញតាមលក្ខណៈវិនិច្ឆ័យមានទម្ងន់ដែលចាំបាច់ឱ្យមានកិច្ចអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះដែរ[15]។ គាត់បានគូសបញ្ជាក់ថា ផលវិបាកដែលថា ការសន្និដ្ឋានអវិជ្ជមាន "អាច" ត្រូវធ្វើឡើងដោយផ្អែកលើប្រតិចារឹកក្នុងសំណុំរឿង ០០២ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០៤ គឺជាការប៉ាន់ស្មានសុទ្ធសាធ[16] ហើយថា ការដាក់ភស្តុតាងដាក់បន្ទុកទៅក្នុងសំណុំរឿងពុំមែនជាព្យសនកម្មមួយដែលគេអាចដឹងបាននោះទេ[17]។ គាត់បានលើកឡើងបន្ថែមថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនគួរយកមកប្រើដើម្បីសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍ដែលស្នើសុំដាក់ឧទ្ធរណ៍បន្ថែមដែលបានលើកឡើងនៅក្នុងនីតិវិធីមោឃភាពដោយឡែកដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំរួចមកហើយនោះ អាចទទួលយកបាននោះឡើយ[18]។

## ខ. ការពិភាក្សា

---

[11] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១២។

[12] *ដូចយោងខាងលើ*។

[13] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

[14] ចម្លើយតប កថាខណ្ឌ ២-៦។

[15] ចម្លើយតប កថាខណ្ឌ ២។

[16] ចម្លើយតប កថាខណ្ឌ ៣។

[17] ចម្លើយតប កថាខណ្ឌ ៤។

[18] ចម្លើយតប កថាខណ្ឌ ៥ *យោងទៅ* សំណុំរឿង ០០៤ ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D360/1/1/2។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

8. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្តឹងឧទ្ធរណ៍មិនស្ថិតក្នុងយុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុងទេ។ អង្គជំនុំជម្រះរម្លឹកបន្ថែមថា ទោះបីវិធាន ២១ នៃវិធានផ្ទៃក្នុងអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះប្រកាន់យកការបកស្រាយក្នុងន័យទូលាយអំពីសិទ្ធិប្តឹងឧទ្ធរណ៍ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងចំពោះមុខក៏ដោយ តែវិធាននេះមិនបានផ្តល់នូវមធ្យោបាយស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ ដែលលើកឡើងពីទឡ្ហីករណ៍ផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈពិសេសនៃរឿងក្តីដែលកំពុងពិនិត្យនេះ អន្តរាគមន៍របស់អង្គបុរេជំនុំជម្រះគឺជាការចាំបាច់ដើម្បីរារាំង*ព្យសនកម្មដែលមិនអាចជួសជុលបាន*ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[19]។

9. នៅក្នុងសំណុំរឿងនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា ប្រសិនបើដីកាសម្រេចដែលរងការជំទាស់មិនត្រូវបានច្រានចោល សិទ្ធិរបស់គាត់ដែលបានអះអាងអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង នឹងស្ថិតក្នុងហានិភ័យនៃការខូចខាតដែលមិនអាចជួសជុលបាននោះឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានព្យសនកម្មដែលមិនអាចជួសជុលបានចំពោះសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ កើតឡើងដោយសារតែការដាក់ភស្តុតាងដាក់បន្ទុកទៅក្នុងសំណុំរឿងនោះទេ។ ការពិត នៅដំណាក់កាលនេះ អ្វីដែលអាចប៉ាន់ស្មានគឺថា តើសហចៅក្រមស៊ើបអង្កេតនឹងសំអាងទៅលើសម្ភារៈដែលដាក់ក្នុងសំណុំរឿង ០០៤ ក្នុងការរៀបរៀងសេចក្តីព្រាងនៃដីកាដំណោះស្រាយ ដែលអាចប្តឹងឧទ្ធរណ៍បាន ឬយ៉ាងណា។ ជាពិសេស អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចដែលរងការជំទាស់លើកឡើងថា ប្រតិចារឹកពីសំណុំរឿង ០០២ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០៤ "*អាច*ជាមធ្យោបាយត្រឹមត្រូវ និងមានប្រសិទ្ធផលដើម្បីបញ្ជាក់ និងវាយតម្លៃភាពអាចទុកចិត្តបានលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយ"[20] ហើយ "*អាច*ជួយ[ឱ្យសហចៅក្រមស៊ើបអង្កេត]វាយតម្លៃភាពអាចទុក

---

[19] *សូមមើលឧទាហរណ៍* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៤) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D351/2/3 កថាខណ្ឌ ៨។ សំណុំរឿង ០០៤ (អបជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D284/1/4 កថាខណ្ឌ ២១។

[20] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣១ [គូសបញ្ជាក់បន្ថែម]។

ចិត្តបាន និងភាពជឿជាក់បានលើ[កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានដាក់ក្នុងសំណុំរឿងរួចហើយ]"[21]។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ព្យសនកម្មដែលបានចោទប្រកាន់គឺជាសម្មតិកម្ម ហើយបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ**បណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧**

**ប្រធាន** | **អង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន** Olivier BEAUVALLET **ន័យ ថុល** Kang Jin BAIK **ហួត វុទ្ធី**

[21] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៣ [គូសបញ្ជាក់បន្ថែម]។